**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣១៣
ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩
**សាលដីកា**
លេខ:១៣៧
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក .............. ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ..............

**តំណាងមហាអយ្យការ**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ២៥០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤២៩ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទអ្នកស្រីធស ជាចុងបណ្តឹងសាទុក្ខ អាយុ៤២ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ក្រុមទី៨ ផ្លូវព្រះមុនីវង្ស សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា ។ ឪពុកឈ្មោះឆេង ស្រេង ( ស ) ម្តាយឈ្មោះហ៊ី ម៉ែ ( ស ) ប្តីឈ្មោះ សំ ភុងសាន្ត ។

មានមេធាវីលោក .............

និងចុងចម្លើយលោក សកស ជាម្ចាស់បណ្តឹងសាទុក្ខ អាយុ៥០ឆ្នាំ ជាតិខ្មែរមុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃក្រុមទី៤ មណ្ឌល២ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះសំ សរ ( ស ) ម្តាយឈ្មោះម៉ម ភាច( ស ) ប្រពន្ធឈ្មោះធស ។

មានមេធាវីលោក ...........

**អំពីវិវាទ** ប្តឹងសុំផ្តាច់សមគ្គសង្វាស

បានឃើញបណ្ដឹងសាទុក្ខលេខ២៦៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ របស់ ភស ប្ដឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណីលេខ២៥០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣១៣ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការកំពូល

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៩-០៨-៩៧ របស់អ្នកស្រីធស បានប្ដឹងសុំផ្ដាច់ សមគ្គសង្វាស ពីប្ដីឈ្មោះសភស ដោយអាងហេតុថា ចាប់តាំងពីឆ្នាំ១៩៨៨ ខ្លួនបានយកគ្នាជាប្ដី ប្រពន្ធដោយមានរដ្ឋអំណាចដឹងឮត្រឹមត្រូវ ។ ចាប់តាំងពីរួមរស់ជាមួយគ្នា មកខ្លួនពុំដែលបានសេចក្ដីសុខទេ ព្រោះប្ដីខ្លួនចេះតែរករឿងឈ្លោះប្រកែក វាយដំ ជេរប្រមាថ ដល់ពូជអំបូរខ្លួន ម្យ៉ាងទៀតប្ដីរបស់ខ្លួនបាន យកលុយពីផ្ទះដើរចាយវាយ មិនគិតគូរដល់គ្រួសារទេ ហើយថែមទាំងចុះចេញពីផ្ទះ ដោយយកទ្រព្យសម្បត្តិ មួយចំនួនទៅជាមួយ ដែលធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា និងសុំចែកទ្រព្យសម្បត្តិរួម ។

បានឃើញ ដីកាសម្រេចតាមពាក្យសុំលេខ៧៨៥ គរ.៩៧ ចុះថ្ងៃទី១១ ខែធ្នូឆ្នាំ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ ដែលបានសម្រេចៈ

១- ទទួលពាក្យសុំរបស់លោកស្រីធស ចុះថ្ងៃទី២៥ ខែ៨ ឆ្នាំ១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ហាមលក់ ហាមដូរ ហាមបញ្ចាំ ហាមធ្វើប័ណ្ណកម្មសិទ្ធិ និងការធ្វើអំណោយផ្សេងៗ នូវ ដីចំនួន ៥៥ហិកតាជាង ដែលស្ថិតនៅម្ដុំពយ ម៉ាចូវ ក្នុងសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលជាកម្មសិទ្ធិរួមរបស់លោកសភស និង អ្នកស្រីធសទុកជាបណ្ដោះអាសន្នសិន រង់ចំតុលាការ សម្រេចដល់អង្គសេចក្ដី នៃរឿង ។

៣-ដីកានេះ បើភាគីណាមួយមិនសុខចិត្ត មានសិទ្ធិប្ដឹងមកតុលាការក្រុងព្រះសីហនុ យ៉ាងប្រញាប់បំផុត ។

៤-បង្គាប់មកលោកប្រធានភូមិបាលខណ្ឌព្រៃនប់ និងលោកប្រធានសុរិយោដីក្រុងព្រះសីហនុ អនុវត្តដីកានេះ ឱ្យមានប្រសិទ្ធិភាព ។

បានឃើញ ដីកាសម្រេចបញ្ចូលតតិយជនមកជាគូក្ដីលេខ១៤០ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៨ របស់ តុលាការក្រុងព្រះសីហនុ ដែលបានសម្រេចៈ

១- បញ្ចូលឈ្មោះអ្នកស្រីបរអាយុ២៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១៥ សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

២- បញ្ចូលឈ្មោះអ្នកស្រីថអអាយុ២៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១១ សង្កាត់ ផ្សារថ្មី នោះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៣- បញ្ចូលឈ្មោះអ្នកស្រីបជអាយុ២៥ឆ្នាំ ជាតិខ្មែរមានទីលំនៅក្រុមទី៤៤ សង្កាត់អូរឫស្សីទី៣ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

ដែលមានប័ណ្ណកម្មសិទ្ធិនៅលើដីរបស់អ្នកស្រីធស និងលោក សភស ជាតតិយជនមកជាគូក្តីខាងចុងចម្លើយចាប់ពីពេលនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ៥៩ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងព្រះសីហនុ សម្រេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឲ្យអ្នកស្រីធស និងលោកសភស ដាច់សមគ្គសង្វាសពីគ្នា ចាប់តាំពីថ្ងៃសាលក្រមនេះ ក្លាយទៅជាសាលក្រមស្ថាពរតទៅ ។

៣-ឱ្យអ្នកស្រី ធស ស្ថិតក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតចាប់តាំងពីថ្ងៃបែកលំនៅសង្វាសតទៅ ។

៤- ទ្រព្យសម្បត្តិដីនៅចំណោតអូរត្រាវ មានប័ណ្ណកម្មសិទ្ធិលេខ$C_1$០១០៥ មានទំហំ៥ហិកតា ដីស្ថិតនៅម្តុំពយព្រឹង ពុំទាន់មានប័ណ្ណកម្មសិទ្ធិ មានទំហំ៥៣៧,៣៨៩ម²ដោយគិតពីផ្ទុំពយព្រឹងមកអារផ្តៅផ្នែកខាងក្រោមជាប់សមុទ្រ ឯផ្នែកខាងលើភ្នំ ទៅទល់ និងផ្លូវឡានវីដេអូ មួយកំប្លេរ ចង្រ្កានេហ្គាសមួយ ទូទឹកកកមួយគ្រឿង ម៉ាញ៉ាមួយគ្រឿង និង សំភារៈប្រើប្រាស់ប្រចាំថ្ងៃប្រគល់ឱ្យអ្នកស្រី ធស គ្រប់គ្រង ជាម្ចាស់កម្មសិទ្ធីរីងដីសង់លំនៅដ្ឋានមួយច្បត៏ស្ថិតនៅសង្កាត់៤ ខណ្ឌមិត្តភាព ដីនៅម្តុំរោងចក្រប្រេងកាតទំហំ៥ហិកតា ៧០អា ពុំទាន់មានប័ណ្ណកម្មសិទ្ធិ ដីនៅម្តុំពយព្រឹងចំនួន៣០០.០០០ម² ដែលសល់ពីដីដែលចែក ឱ្យដើមចោទ សិប្បកម្មធ្វើទ្វា និងបង្អួច០២ កន្លែង គឺនៅភ្នំពេញមួយកន្លែង និងក្រុងព្រះសីហនុមួយកន្លែង ម៉ាស៊ីនក្រឡឹងមួយគ្រឿង ម៉ាស៊ីនលាយស៊ីម៉ងត៍មួយគ្រឿង ត្រើយស្គូចមួយគ្រឿង ម៉ូតូ០២គ្រឿង ប្រគល់ឱ្យលោក សភស គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិចាប់តាំងពីថ្ងៃដែលសាលក្រមនេះ ក្លាយជាសាលក្រម ស្ថាពរតទៅ ។

៥-ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជី២០០៛ រង្វាន់ប្រគល់ដីកាកោះ៥០០០៛ សរុប៧០០០៛ តែប្រាក់នេះ បានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយកាលបើផុតឧទ្ធរណ៍ទើបបង្គាប់ឱ្យចុងចម្លើយបង់សងទៅដើមចោទជាក្រោយ ។

៦-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុង ចម្លើយទុកសិទ្ធិឱ្យគូភាគីប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣២ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោកសកស ប្តឹងមិនសុខចិត្ត នឹងសាលក្រមលេខ៥៩ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការ ក្រុងព្រះសីហនុ លើត្រង់ចំណុចទាំងស្រុង នៃសាលក្រម ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តី សម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥-០៩-៩៨ របស់ឈ្មោះសកស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៥៩ ចុះថ្ងៃទី២៦-០៦-៩៨ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់លេខ០៦ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់លោកសកស (បានទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៧-០១-៩៩) ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសាលដីការទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ២៥០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេច ដូចតទៅៈ

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០១-០២-៩៩ របស់ឈ្មោះសកស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ៣១ ចុះថ្ងៃទី១៩-០១-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះដើមចោទកំបាំងមុខចុងចម្លើយ តែទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ២៦៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ របស់លោកសកស ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ២៥០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី១៦-០៣-២០០០ របស់លោកសភស

បានឃើញសារណាតប ចុះថ្ងៃទី១៣-១២-២០០០ របស់អ្នកស្រី ធស

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា : រឿងនេះជាវិវាទ ប្តឹងសុំផ្តាច់សមគ្គសង្វាស ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះសភស ឆ្លើយថាៈទំនាក់ទំនងស្នេហារវាងខ្លួន និងអ្នកស្រីធស មានកំរិតត្រឹមតែជាស្រីកំណាន់ចិត្តលួចលាក់តែប៉ុណ្ណោះ ខ្លួនពុំដែលបានរៀបចំពិធីអាពាហ៍ពិពាហ៍ ឬ ក៏ចុះចំណងអាពាហ៍ពិពាហ៍ នៅកន្លែងរដ្ឋអំណាចអាត្រានុកូលដ្ឋានម្តងណាទេ ។

ចំពោះការដែលអ្នកស្រីធសថគាត់បានរូបខ្លួនជាប្តី តាំងពីឆ្នាំ១៩៨៨ ដោយមានពិធីសែនព្រេនផងនោះ គឺជាការនិយាយកុហក ព្រោះថា នៅឆ្នាំ១៩៨៨ ប្រពន្ធដើមរបស់ខ្លួន ឈ្មោះនសយបានរស់នៅជាមួយខ្លួនជាប់ជានិច្ច ដោយរូបខ្លួនជាប្រធានរោងចក្រទឹកកកសម័យកម្ពុជាប្រជាមានិត ជាសម័យសង្គមនិយម តើកម្មាភិបាលណាមួយដែលរដ្ឋអនុញ្ញាតឱ្យយកប្រពន្ធពីរនោះ គឺពុំអាចមានលទ្ធភាព
ទាល់តែសោះ ។ ហើយអ្នកស្រី ធស ក៏មានប្តីដែរ ។

ចំពោះដីនៅពយព្រឹង និងដីនៅក្បែររោងចក្រប្រេងកាត ដែលអ្នកស្រីប្តឹងទាមទារនោះក៏ជារបស់លោកឡសលោកអសរ, លោកឈហនិងលោកឧបឌដែរ ។

ក្រឡាបញ្ជីអាន សារណាតប របស់អ្នកស្រី ធស ។

លោក........... មេធាវីការពារឱ្យចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថា ការទំនាស់ គឺលើដីមួយកន្លែងគ្មានកម្មសិទ្ធិ ហើយនោះពុំដល់៨០ ហិកតាទេ គឺប្រហែល៤០ ហិកតាទេ ។ ហើយសាលាឧទ្ធរណ៍សម្រេចចូលដីរបស់គេ ។ ហើយការដែលដើមចោទទាមទារទ្រព្យរួមនោះ ក៏ពុំត្រឹមត្រូវដែរ ព្រោះថា នៅឆ្នាំ១៩៨៨ លោក សភស មានប្រពន្ធត្រឹមត្រូវហើយអ្នកស្រីធគក៏មានប្តីដែរ។

ដូច្នេះខ្ញុំសុំឱ្យក្រុមប្រឹក្សាជំនុំជំរះ ពិចារណាអំពីចំណងអាពាហ៍ពិពាហ៍ និងសុំបដិសេធសាលដីការរបស់សាលាឧទ្ធរណ៍ ។

លោក.............មេធាវីការពារឱ្យដើមចោទ ធ្វើសេចក្តីសន្និដ្ឋានថាឈ្មោះសភស និងអ្នកស្រីធសជាប្តីប្រពន្ធ និងគ្នា ដោយមានចាស់ទុំដឹងឮ ដោយមានការសែនព្រេន និងរដ្ឋអំណាច ទទួលស្គាល់ ។ ម៉្យាងទៀត ក្នុងប្រវត្តិរូបរបស់លោកសភស ក៏ដាក់ឈ្មោះធេង គឹមដែរ ចំណែកប្រពន្ធដើមគាត់ឈ្មោះ នសយ។ ដូច្នេះឈ្មោះ ធគវាដូចគ្នានឹងឈ្មោះធស ។

អាស្រ័យហេតុនេះ ខ្ញុំសូមឲ្យឯកឧត្តមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោកសភស សារណារបស់អ្នកស្រីធស និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៦៣ ចុះថ្ងៃទី៣០-០៧-៩៩ របស់លោកសភស ស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាការដែលលោកសភស លើកឡើងក្នុងសារណារបស់លោក និងក្នុងពេលសវនាការនេះថាលោក និងអ្នកស្រីធសពុំមានចំណងអាពាហ៍ពិពាហ៍ពាមផ្លូវច្បាប់ទេ គឺជាស្រីកំណាន់បែបអនីតិសង្វាសនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចូលជាធរមាននៅឆ្នាំ១៩៨៩ ហើយលោក និងអ្នកស្រីធស រួមរស់ជាមួយគ្នានៅឆ្នាំ១៩៨៨ ឬ ១៩៨៩ ដូច្នេះនៅពេលនោះ ពុំទាន់មានសៀវភៅខ្លួនអាពាហ៍ពិពាហ៍ទេ ។ ប៉ុន្តែទោះបីពុំបានចុះអាពាហ៍ ពិពាហ៍ ក៏ប៉ុន្តែលោកសភសបានទទួលស្គាល់នូវចំណងអាពាហ៍ពិពាហ៏នេះ ច្បាស់លាស់ណាស់នៅក្នុង កំណត់ហេតុ ផ្សះផ្សា ចុះថ្ងៃទី២៨-០៣-៩៤ មុខតុលាការក្រុងព្រះសីហនុថា ការប្តឹងសុំផ្តាច់សមគ្គសង្វាស របស់ប្រពន្ធលោក លោកមិនទាន់អស់មនោសញ្ចេតនាពីប្រពន្ធលោកទេ ពីព្រោះលោកនៅតែស្រលាញ់ប្រពន្ធ របស់លោកដដែល លោកបានគ្នាជាប្តីប្រពន្ធនេះ ដោយលំបាកលំបិនណាស់ មានចំណងអនុស្សាវរីយ៍ ដែលមិនអាចបំភ្លេចបាន ដូច្នេះលោក សុំបន្តរួមរស់ជាមួយប្រពន្ធរបស់លោកបន្តទៀត ហើយប្រវត្តិរូប ដែលលោក សរសេរដោយផ្ទាល់ខ្លួនលោកនៅឆ្នាំ១៩៩៣ ក៏លោកបញ្ជាក់ដែរថា អ្នកស្រីផសជាប្រពន្ធរបស់លោក។

-យល់ឃើញថា ការដែលលោកសភស លើកឡើងនៅក្នុងសារណា ក៏ដូចជានៅពេលសវនាការនេះដែរ ដែលថា លោកពុំសុខចិត្តប្រគល់ដីនៅភូមិអូរត្រាវចំនួន០៥ហិកតា ដែលមានប័ណ្ណសម្គាល់សិទ្ធិលេខ$C_1$០១០៥ និងដីនៅពយព្រីង ឃុំបិតត្រាង ឲ្យទៅអ្នកស្រីធស ដោយហេតុថា ដីនេះ មិនមែនជាទ្រព្យសម្បត្តិរួមទេ គឺជាដីដែលលោកទិញដោយប្រាក់ដើមរបស់លោក បានមកពីការលក់ដីរួមជាមួយសពប្រពន្ធមុនរបស់លោកនោះពុំមានភស្តុតាងគួរឱ្យជឿបានឡើយ ពីព្រោះដីនេទិញនៅក្នុង ចំណងអាពាហ៍ពិពាហ៍ជាមួយអ្នកស្រីធស ហើយពុំមានភស្តុតាងណាបញ្ជាក់ថាលុយទិញដីនេះ ជាលុយ ទ្រព្យដើមរបស់លោកទេ ។

-យល់ឃើញថា ទ្រព្យសម្បត្តិ ដែលតុលាការបានប្រគល់ឱ្យលោក សំភស ហើយដែលកំពុងស្ថិតនៅលើដៃរបស់លោកសភស មានចំនួនច្រើនជាងទ្រព្យសម្បត្តិ ដែលតុលាការបានប្រគល់ឱ្យអអ្នកស្រីធស មែនប៉ុន្តែអ្នកស្រីធស ពុំបានទាមទារអ្វីលើសពីនេះដៃ លើកលែងតែដីនៅពយព្រឹងដែលពុំទាន់ស្ថិត

នៅក្នុងការកាន់កាប់របស់ភាគីណា ដែលអ្នកស្រីឆស ទាមទារចំណែកលើសពីពាក់កណ្តាល ។ ដូច្នេះ ការសម្រេចសេចក្តីរបស់តុលាការថ្នាក់ក្រោម មានលក្ខណៈត្រឹមត្រូវតាមសមធម៌ហើយ ។

- យល់ឃើញថា ការដែលលោកសកស លើកឡើងនៅក្នុងពេលសវនាការនេះថា ដីនៅពយព្រឹង មានតែជាង៥០ ហិកតា យកមកធ្វើការបែងចែកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតុលាការបែងចែកដូចនេះ ដោយហេតុថា មន្ត្រីតុលាការបានសហការជាមួយភូមិបាលខណ្ឌ ព្រៃនប់ ចៅសង្កាត់រងបិតត្រាំបានចុះវាស់វែងដីទំនាស់នេះ តាមកំណត់ហេតុចុះថ្ងៃទី១៧-០១-៩៨ និងតាមប្លង់ចុះថ្ងៃទី២១-០១-៩៨ (ឯកសារលេខ១៨) ឃើញថាក្នុងរង្វចង់ទីតាំងដីទំនាស់នេះ មានផ្ទៃដីក្រឡា៤៤៥,៨៥៦ម២+២០៨,៥៣៨ម២+១៣៥០០០ម២+៤៧,៩៩៥ម២ =៨៣៧,៣៨៩ម២ គឺត្រឹមត្រូវតាមទំហំដីដែលតុលាការថ្នាក់ក្រោមបានលើកយកមកធ្វើការបែងចែកហើយ ។

-យល់ឃើញថា ការដែលលោកសកស លើកឡើងថា ដីចំនួន៣០០.០០០ម២ នៅពយព្រឹង ដែលតុលាការថ្នាក់ក្រោមប្រគល់ឱ្យលោកនេះ គឺជាដីអ្នកដទៃ លោកពុំអាចទទួលយកបានទេ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះនៅលើគំនូសប្លង់ ចុះថ្ងៃទី២១-០១-៩៨(ឯកសារលេខ១៨) ដែលតុលាការទទួលស្គាល់ នៅក្នុងរង្វង់ដីទំនាស់ មានឃើញដីកម្មសិទ្ធិរបស់ឈ្មោះបរទំហំ១៣៥០០០ម២ ហើយ+៤៧៩៩៥ម២=១៨២៩៩៥ម២ តែប៉ុណ្ណោះ ហើយតុលាការមុននឹងសម្រេចសេចក្តីក្នុងរឿងក្តីនេះ ក៏បាន ចាត់បញ្ចូលឈ្មោះបរ មកជាតតីយជន ខាងចុងចម្លើយរួចហើយ តាមដីកាសម្រេចលេខ១៤០ ចុះថ្ងៃ ៰០៦-ទី០៤-០៣-៩៨ និងបានកោះហៅឈ្មោះបរ និងអ្នកពាក់ព័ន្ធពីរនាក់ទៀត តាមដីកាកោះ ចុះថ្ងៃទី០៦-០៣-៩៨ មកបំភ្លឺដែរ ប៉ុន្តែសាមីខ្លួនពុំបានចូលខ្លួនមកតុលាការទេ ហើយក៏ពុំមានការប្តឹងទាស់ ឬ ប្តឹង ឧទ្ធរណ៍ដែរ ។ ដូច្នេះបើនៅពេលអនុវត្តសាលដីកា មានតតីយជនមក ប្តឹងទាស់តុលាការអាចលើកយកដី នៅពយព្រឹងទាំងចំណែកត្រូវបានទៅលោកសកស ទាំងចំណែកត្រូវបានទៅខាងអ្នកស្រី ឆស មកពិចារណា និងសម្រេចជាថ្មីបាន។ ប៉ុន្តែក្នុងករណីដែល គ្មានការប្តឹងទាស់ទេ តុលាការត្រូវតម្កល់នៅទំហំដីនេះ ទុកជាបានការ ។

-យល់ឃើញថាអ្នកស្រីឆស បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយប៉ុន្តែ ពុំបានមកចូលរួមអាសវនាការនេះទេ មានតែមេធាវី មកចូលរួម ដូច្នេះ តុលាការកំពូលជំនុំជំរះ កំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៥០ ចុះថ្ងៃទី២០-០៥-៩៩ របស់សាលា ឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## ១សេចក្ដីសម្រេចចំពោះមុខលោកសកស កំបាំងមុខអ្នកស្រីឆស ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ២៦៣ ចុះថ្ងៃទី៣០-០៧-៩៩ របស់លោកសកស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ២៥០ ចុះថ្ងៃទី២០-០៥-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ដែលលោក សកស បានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០៛ គឺ:

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ។